# ថ្នាំបង្ការជំងឺ COVID-19៖ ប្រភេទ Pfizer និងប្រភេទ Moderna
## ពេលវេលានៃការទទួលចាក់ដូសទីពីរនៃលំដាប់ដំបូង

### តើខ្ញុំគួរទទួលចាក់ថ្នាំបង្ការដូសទី 2 នៅពេលណា?




ប្រសិនបើអ្នកទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ប្រភេទ Pfizer ឬប្រភេទ Moderna អ្នកនឹងត្រូវចាំបាច់ទទួលចាក់ចំនួន 2 ដូសដើម្បីបញ្ចប់ការចាក់លំដាប់ដំបូង។ ពេលវេលាដែលល្អបំផុតសម្រាប់ការទទួលចាក់ដូសទី 2 នៃលំដាប់ដំបូង គឺអាស្រ័យទៅលើស្ថានភាពរៀងៗខ្លួនរបស់អ្នក។

**ប្រសិនបើអ្នកមានអាយុក្រោម 65 ឆ្នាំ ហើយអ្នកមិនមានប្រព័ន្ធភាពសុំាខ្សោយទេនោះ៖**

- អ្នកប្រហែលជាអាចទទួលបានអត្ថប្រយោជន៍ពីការទទួលចាក់ដូសទីពីរនៃលំដាប់ដំបូងរបស់អ្នកនៅក្នុងពេល 8 សប្តាហ៍បន្ទាប់ពីការចាក់ដូសទីមួយរបស់អ្នក ជាពិសេសប្រសិនបើអ្នកគឺជាមនុស្សប្រុសដែលមានអាយុចាប់ពី 12 ទៅ 39 ឆ្នាំ។ នេះក៏ព្រោះតែការចំណាយពេលកាន់តែយូររវាងដូសទីមួយ និងដូសទីពីរ ហាក់ដូចជាបង្កើនកម្រិតនៃប្រព័ន្ធការពារដែលថ្នាំបង្ការនេះអាចផ្តល់ជូន ហើយក៏កាត់បន្ថយហានិភ័យនៃបញ្ហា myocarditis (ការរលាកសាច់ដុំបេះដូង) ដែលកម្រនឹងកើតមានរួចហើយនោះផងដែរ។ បុរសវ័យក្មេង (ដែលមានអាយុចាប់ពី 12 ទៅ 39 ឆ្នាំ) ប្រឈមនឹងហានិភ័យខ្ពស់បំផុតនៃការកើតមានបញ្ហារលាកសាច់ដុំបេះដូងនេះ។
- ប្រសិនបើអ្នកត្រូវការប្រព័ន្ធការពារឲ្យបានពេញលេញតាមដែលអាចធ្វើទៅបាន កាន់តែឆាប់នោះ អ្នកគួរតែទទួលចាក់ដូសទីពីរនៃលំដាប់ដំបូងរបស់អ្នកឲ្យបានលឿនជាងមុន៖ យ៉ាងហោចណាស់រយៈពេល 3 សប្តាហ៍បន្ទាប់ពីការចាក់ដូសទី 1 នៃថ្នាំបង្ការប្រភេទ Pfizer របស់អ្នក និងយ៉ាងហោចណាស់រយៈពេល 4 សប្តាហ៍បន្ទាប់ពីការចាក់ដូសទី 1 នៃថ្នាំបង្ការប្រភេទ Moderna របស់អ្នក។ ឧទាហរណ៍នៃចំណុចនេះ គឺប្រសិនបើមានការរីករាលដាលកម្រិតខ្ពស់នៅតាមទីកន្លែងដែលអ្នករស់នៅ ធ្វើការ ឬធ្វើដំណើរ និង/ឬ ប្រសិនបើអ្នកប្រឈមនឹងហានិភ័យខ្ពស់ជាងមុនក្នុងការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ។
- សូមពិគ្រោះជាមួយគ្រូពេទ្យរបស់អ្នក ប្រសិនបើអ្នកមិនប្រាកដថា តើពេលណាមួយដែលល្អបំផុតសម្រាប់ស្ថានភាពរបស់អ្នកនោះ។

**ប្រសិនបើអ្នកមានប្រព័ន្ធភាពសុំាចុះខ្សោយកម្រិតមធ្យម ឬកម្រិតធ្ងន់ធ្ងរ និង/ឬ មានអាយុចាប់ពី 65 ឆ្នាំឡើងទៅ៖**



- អ្នកគួរតែទទួលចាក់ដូសទីពីរនៃលំដាប់ដំបូងរបស់អ្នកឲ្យបានលឿនជាងមុន - យ៉ាងហោចណាស់រយៈពេល 3 សប្តាហ៍បន្ទាប់ពីចាក់ដូសទី 1 នៃថ្នាំបង្ការប្រភេទ Pfizer របស់អ្នក និងយ៉ាងហោចណាស់រយៈពេល 4 សប្តាហ៍បន្ទាប់ពីចាក់ដូសទី 1 នៃថ្នាំបង្ការប្រភេទ Moderna របស់អ្នក។
- អ្នកក៏គួរតែទទួលចាក់ដូសទី 3 នៃលំដាប់ដំបូង យ៉ាងហោចណាស់រយៈពេល 4 សប្តាហ៍បន្ទាប់ពីចាក់ដូសទី 2 រួចផងដែរ ប្រសិនបើអ្នកមានប្រព័ន្ធភាពសុំាចុះខ្សោយ។

ប្រសិនបើអ្នកមានការយឺតយ៉ាវក្នុងការទទួលចាក់ដូសទីពីរ សូមព្យាយាមទទួលចាក់ឲ្យបានកាន់តែឆាប់តាមដែលអាចធ្វើទៅបាន។ អ្នកអាចបន្តចាក់លំដាប់ថ្នាំបង្ការបន្ទាប់ពីដូសលើកចុងក្រោយដែលអ្នកបានចាក់។ អ្នកមិនចាំបាច់ចាប់ផ្តើមការចាក់ឡើងវិញ ចាប់ពីដូសទីមួយទៅនោះទេ។

សម្រាប់ព័ត៌មានបន្ថែម សូមចូលមើលគេហទំព័រ ph.lacounty.gov/covidvaccineschedules។